# ការសម្ភាសរបស់ ខាន់ គីមយ៉េង

កៈ អ្នកសម្ភាស ញ៉ែម សុគន្ធា ខៈ អ្នកត្រូវគេសម្ភាស ណាន ស្រី

កៈ ចឹងជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលឱ្យខ្ញុំសម្ភាសអំពីជីវប្រវត្តិរបស់អ្នកមីងនាងខ្ញុំឈ្មោះ ញ៉ែម សុគន្ធា ជាអ្នកសម្ភាស ចឹងអ្នកមីងតើឈ្មោះពេញរបស់អ្នកមីងឈ្មោះពេញឈ្មោះអីគេដែរ?

ខៈ ខ្ញុំឈ្មោះ ណាន ស្រី។

កៈ អីគេដែរ?

ខៈ ណាន ស្រី។

កៈ ចឹងថ្ងៃនេះខ្ញុំសម្ភាសអ្នកមីង ណាន ស្រី នៅក្នុងថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៦ ។ ការសម្ភាសនេះត្រូវបានរៀបចំឡើងដោយសាកលវិទ្យាល័យនៅប្រទេសអាមេរិចដែលមានឈ្មោះ ថា ប៊ី វ៉ាយ យូ សាកលវិទ្យាល័យមានកម្មវិធីដើម្បីសម្ភាសអំពីជីវប្រវត្តិរបស់អ្នកមីង និងប្រជា ពលរដ្ឋខ្មែរ ដើម្បីទៅមុខទៅកូនចៅរបស់អ្នកមីង និងមនុស្សជំនាន់ក្រោយអាចដឹងអំពីជីវ ប្រវត្តិ និងដំនើររឿងក៏ដូចជាឆាកជីវិតរបស់អ្នកមីងក៏ដូចជាឆាកជីវិតដូនតាផងដែរ តើអ្នកមីងអនុញ្ញាតដើម្បីឱ្យខ្ញុំដាក់ការសម្ភាសនេះចូលទៅក្នុងវេបសាយរបស់សាកលវិទ្យាល័យ ប៊ី វ៉ាយ យូ ដែរឬទេអ្នកមីង?

ខៈ បាន។

កៈ ចាស ដែលវេបសាយនេះមានឈ្មោះថា www.cambodiaoralhistory.byu.edu ហើយ នាងខ្ញុំសូមចាប់ផ្ដើមធ្វើការសម្ភាសដល់អ្នកមីង ។ ចឹងអ្នកមីងសូមប្រាប់ឈ្មោះពេញរបស់អ្នកមីងម្ដងទៀត?

ខៈ ឈ្មោះ ណាន ស្រី ។

កៈ អ្នកមីងមានឈ្មោះហៅក្រៅទេ?

ខៈ ហៅតែស្រីៗ។

កៈ ស្រីៗ ទទេ!

ខៈ  យកឈ្មោះរៀនអត់ ហីអត់ទេ?

កៈ ចាសៗ។

ខៈ ឈ្មោះរៀនហ្ន?

កៈ ចាស។

ខៈ  ឈ្មោះរៀន ខាន់ គឹមយ៉េង។

កៈ ចឹងឈ្មោះនៅក្នុងបញ្ជីជាតិរបស់អ្នកមីងឈ្មោះអីគេ?

ខៈ ខាន់ គឹមយ៉េន។

កៈ  ចឹងឈ្មោះស្រីហ្នឹងគេហៅខាងក្រៅទេ?

ខៈ  ហៅក្រៅទេ។

កៈ  ចាស ចឹងអ្នកមីងតើអ្នកមីងកើតនៅថ្ងៃខែឆ្នាំណាដែរ?

ខៈ ឆ្នាំ១៩៦៨។

កៈ ១៩៦៨! ចាំខែទេ?

ខៈ  ខែអីទេនេះអត់ចាំខែទេ ចាំតែឆ្នាំ។

កៈ  ចាស អត់អីទេ។ ចឹងអ្នកមីងទីកន្លែងកំនើតអ្នកមីងនៅឯណាវិញ?

ខៈ  នៅទន្លេបិទ។

កៈ  ទន្លេបិទ។ ស្រុកអី ឃុំអីដែរមីង?

ខៈ  យកសម័យឥឡូវម៉ងហេ?

កៈ ពីមុនហាំ?

ខៈ  ពីមុនឃុំទន្លេបិទ ភូមិទន្លេបិទ ខេត្តកំពង់ចាម ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

កៈ ដល់ពេលឥឡូវដូរម៉េចវិញមីង?

ខៈ អើភូមិទន្លេបិទ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

កៈ ចាស ឥឡូវប្តូរមកត្បូងឃ្មុំវិញឥឡូវ?

ខៈ ចាស។

កៈ អ្នកមីងឆ្នាំខ្មែរជាសត្វអីគេដែរ?

ខៈ សត្វមាន់។

កៈ ចាស មាន់ រកា!

ខៈ រកា។

កៈ តើមីងមានបង្អូនប្រុសស្រីប៉ុន្មាននាក់ដែរមីង?

ខៈ ខ្ញុំមានរាប់ទាំងស្លាប់ទាំងអស់អីម៉ងហោ?

កៈ ចាសៗ។

ខៈ ទ្រព្យ អាត ខ្ញុំ ៥នាក់។

កៈ បងប្អូន៥នាក់។

ខៈ ចាស។

កៈ មីងជាកូនទីប៉ុន្មានវិញ?

ខៈ ស្រី៥ ប្រុស៤។

កៈ ៩ណោះហោ?

ខៈ ចាស។

កៈ មីងជាកូនទីប៉ុន្មានវិញ?

ខៈ ខ្ញុំបន្ទាប់ពៅទី៣។

កៈ ទី៣ ! ចាស ចឹងអ្នកមីងតើឥឡូវពួកគាត់រស់ឬក៏ពួកគាត់ស្លាប់?

ខៈ ស្លាប់អស់៣នៅ៦។

កៈ នៅ៦!

ខៈ  ចាស។

កៈ ពួកគាត់ដែលនៅរស់ពួកគាត់នៅឯណាខ្លះមីង?

ខៈ  នៅហ្នឹង។

កៈ  នៅទន្លេបិទទាំងអស់?

ខៈ  នៅទន្លេបិទហ្នឹង នៅភ្នំពេញមួយ។

កៈ ចាសហ្នឹងហើយ ចឹងតើអ្នកមីងតើឪពុកមីងគាត់ឈ្មោះអីគេដែរឪពុកហា?

ខៈ ឪពុកឈ្មោះ...

កៈ ឪពុករបស់អ្នកមីងហា?

ខៈ  ឈ្មោះ ណាន។

កៈ អីគេណានវិញ?

ខៈ  ខាន់ ណាន។

កៈ ចឹងតើទីកន្លែងកំណើតរបស់គាត់នៅឯណាវិញមីង?

ខៈ  នៅកោះដាច់។

កៈស្រុកណាវិញមីង។

ខៈ ស្រុកមុខកំពូល។

កៈ ខេត្តកណ្តាល មីងចាំថាគាត់កើតថ្ងៃខែឆ្នាំណាទេ?

ខៈ អត់ដឹងផង តែដឹងថាគាត់កើតឆ្នាំថោះ។

កៈ ចាស! ហ្នឹងហើយ ចឹងដឹងថាគាត់ស្លាប់នៅពេលណាទេមីង?

ខៈ ស្លាប់នៅឆ្នាំប៉ុន្មានទេនេះ ខ្ញុំភ្លេចហើយ គាត់ស្លាប់១០ឆ្នាំជាងទៅហើយ។

កៈ អាយុប៉ុន្មានទៅ?

ខ៖ ពុកខ្ញុំ៨២ឬ៨៣ហើយ។

ក៖ គាត់ស្លាប់១០មុន?

ខ៖ ចាស

ក៖ ចឹង២០០៦?

ខ៖ ប្រហែលល្បាក់ហ្នឹងខ្ញុំអត់ចាំផងដែរ។

ក៖ ចឹងដឹងទេថាតើឪពុកអ្នកមីងកើតឆ្នាំសត្វអីគេដែរ?

ខ៖  ទន្សាយ។

ក៖  ទន្សាយ! ឆ្នាំថោះ ចាស ចឹងតើអ្នកមីងមានការចងចាំអីខ្លះជាមួយឪពុករបស់អ្នកមីង?

ខ៖  ចងចាំពេលដែលរស់នៅជាមួយគាត់ម៉ងហេ?

ក៖ ចាសៗ។

ខ៖ រស់នៅជាមួយគាត់ដឹងថាពិបាកដែរ ។ ពិបាក ដឹងក្ដីមកពិបាករហូតជំនាន់អាពត ដឹងក្ដីមក អាយុ៥ឬ៦ឆ្នាំ។

ក៖ ចាស។

ខ៖ តែយើងអត់បានទៅធ្វើការនៅក្នុងសហករណ៍នៅមើលប្អូន នៅមើលប្អូន២។

ក៖ ចាស។

ខ៖ នៅផ្ទះមើលប្អូន។

ក៖ ចាស ហើយចុះប៉ាមានផ្ដល់ក្ដីស្រលាញ់អីអោយអ្នកមីងហេពេលគាត់បែក ប៉ុល ពត ចឹងហា?

ខ៖ ដូចជាមិនសូវមានភាពកក់ក្ដៅអីដែរ។

ក៖ ចាស។

ខ៖ លំបាក។

ក៖ លំបាកដែរហេ?

ខ៖  ដូចថាគាត់ប្រើយើង  យើងនៅដូចយើងធំជាងគេនៅក្នុងផ្ទះហ្នឹងហា  បងប្រុសៗគាត់អត់ស្ងួរប្រើ ប្រើតែយើងចឹងហា។

ក៖ ចាស!

ខ៖  ស្មៅសេះលើយើង អុស ទឹកអីលើយើងទាំងអស់។

ក៖ ចាស។

ខ៖ ដូចថាយើងអ្នកជំហរតែហ្មង។

ក៖ ចាសហ្នឹងហើយ អ្នកមីងជាបង្គោល។

ខ៖  ចាសហ្នឹងហើយ។

ក៖ ចុះម្ដាយរបស់អ្នកមីងឈ្មោះអីគេដែរ?

ខ៖ ឈ្មោះ ភា ផៃ។

ក៖ ភា ផៃ ចឹងចាំទេថាយាយកើតនៅថ្ងៃខែឆ្នាំណាដែរ?

ខ៖ អត់ចាំថ្ងៃខែទេ គ្រាន់តែចាំឆ្នាំគាត់ ឆ្នាំខាល។

ក៖ ឆ្នាំខាល!

ខ៖ ៨០។

ក៖ ៨០គត់! ចឹង១៩៣៦។ ចាស ហ្នឹងហើយ តើលោកយាយស្លាប់ឬក៏រស់?

ខ៖ នៅរស់តើ។

ក៖ នៅរស់! តើឥឡូវដូចជាគាត់ម៉េចដែរអ្នកមីង?

ខ៖ គាត់ចាស់ខ្លាំងហើយ ពិបាក។

ក៖ ពិបាកម៉េចវិញអ្នកមីង?

ខ៖ គាត់ចង់វង្វេងចឹងហា។

ក៖ចាស។

ខ៖ ចង់វង្វេង ចេះតែដើរបេះនេះ រើសនេះ រើសនោះចឹងទៅ។

កៈចាស។

ខៈ ប្រាប់អោយគាត់នៅផ្ទះគាត់អត់នៅ។

កៈចាស។

ខៈ គាត់ដើរចឹងហើយ ដែលធ្វើអោយញ៉ុមមានការពិបាកចិត្តចឹងហា។

កៈ ចាស។

ខៈ ដោយសារគាត់ចឹង។

កៈ ចាស!

ខៈ យើងឃាត់គាត់កុំអោយដើរបេះដើរបោច គាត់ចេះតែដើររើស ដើរបេះ ដើរបោច គាត់ចាស់ចឹងនៅពិបាកដោយសារគាត់ម្យ៉ាងដែរ។

កៈ ចាស! ចឹងសម្រាប់ដូចជាការរស់នៅជាមួយម៉ាក់មីងពីមុនមកគាត់ផ្តល់ក្តីស្រលាញ់គាត់ដូចជាគាត់ផ្តល់អោយអ្នកមីងច្រើនទេ?

ខៈ ដូចថាស្រលាញ់ហ្នឹងតិចជាង។

កៈ ចាស!

ខៈ ថាអញ្ចេកពេលអាសប្បាយហ្នឹងវាតិចជាង អាពេលទុក្ខ ទុក្ខច្រើនជាងសប្បាយ។

កៈ ចាស!

ខៈ យើងដូចថាសប្បាយពេញលេញដូចគេ ចឹងហា ទៅណាចឹងយើងមិនសូវបានដើរលេងនឹងគេចឹងទេ។

កៈ ហ្នឹងហើយ។

ខៈ ការងារយើងធ្វើរហូត។

កៈ ចាស! ហ្នឹងហើយ ។

ខៈ ការងារប្រុសការងារស្រីលើខ្ញុំទាំងអស់។

កៈ ចាស!

ខ៖ មិនថាប្រុសស្រីនៅលើខ្ញុំទាំងអស់។

ក៖ ចាស។

ខ៖ តាំងពីទឹក តាំងពីអុស ស្មៅសេះ លើខ្ញុំទាំងអស់ បន្ទុកបន្ទាក់លើខ្ញុំមួយចឹងហា។

ក៖ ចាស! ចឹងសម្រាប់អ្នកមីងតើជីតារបស់អ្នកមីងឈ្មោះអីគេដែរ?

ខ៖ ខាងឪពុកហ្អ?

ក៖ ចាស។

ខ៖  កង់ ភា។ ហ្អ ឈ្មោះកង់ខាន់។

ក៖ ចុះយាយ ?

ខ៖  ឈ្មោះយាយ អឹប។

ក៖ យាយអឹប ចឹងចាំទេថាគាត់កើតនៅពេលណាដែរមីង?

ខ៖  អត់ដឹងសោះបើខ្ញុំកើតមកដឹងក្ដីមកអត់ដែលឃើញមុខគាត់ផង។

ក៖ ចុះដឹងស្រុកកំនើតគាត់នៅឯណាអត់?

ខ៖ នៅកោះដាច់។

ក៖ កោះដាច់?

ខ៖ ចាស។

ក៖ ខេត្តកណ្ដាលហ្នឹង។ ចាស ចឹងកើតអត់ទាន់គាត់ទេ?

ខ៖ អត់!

ក៖ ចុះដឹងឆ្នាំសត្វខ្មែរគាត់កើតសត្វអីគេអ្នកមីង?

ខ៖ អត់ដឹងសោះ ។

ក៖ មិញខាងឪពុកឬក៏ខាងម្ដាយ?

ខ៖ មិញហ្នឹងប្រាប់មិញហ្នឹងខាងឪពុក។

កៈ ចុះសម្រាប់ខាងម្ដាយវិញគាត់ឈ្មោះអីគេដែរជីដូនជីតា?

ខៈ ឈ្មោះកង់ភា យាយឈ្មោះយាយប៉ាត់។

កៈ យាយប៉ាត់!

ខៈ ដឹងតែឈ្មោះទេ តែខែឆ្នាំអត់ដែលសួរ។

កៈ ពេលពួកគាត់ស្លាប់ ស្លាប់ក្នុងជំនាន់ណាមីង?

ខៈ តាំងពីជំនាន់គេ គ្រាប់ផ្លោងហ្នូ។

កៈ ចាស!

ខៈ គ្រាប់ផ្លោងជំនាន់ចិតជាងហ្នូ។

កៈ ជំនាន់ លន់ នល់?

ខៈ ចាស ជំនាន់ លន់ នល់។

កៈ កើតទាន់គាត់ទេ?

ខៈ អត់ទាន់។

កៈ អត់ទាំង៤?

ខៈ អត់ទាំង៤។

កៈ ចាស ហ្នឹងហើយ ចឹងអត់អីទេអ្នកមីង។

ខៈ ទាន់ៗខាងឪពុក ជីតាខាងឪពុកទាន់។

កៈ គាត់ម៉េចដែរអ្នកមីង?

ខៈ កាលគាត់ទាន់គាត់ហ្នឹងគាត់ឈឺស្លាប់ទេ។

កៈ គាត់ស្លាប់ពេលណាវិញ?

ខៈ ស្លាប់យូរហើយ ល្បាក់៣០ឆ្នាំហើយ តាំងពីខ្ញុំនៅក្មេងហ្នឹង។

កៈ ចាស!

ខ៖ ពេលហ្នឹងនៅតូច។

ក៖ ចឹងអត់មានអនុស្សាវរីយ៍អីជាមួយគាត់ទេហី?

ខ៖ អត់គ្រាន់តែថាគាត់មកលេងផ្ទះចឹងទៅ ទិញនេះទិញនោះអោយគាត់ហូបតែប៉ុណ្ណឹងឯង។

ក៖ ហ្នឹងហើយ! ចាស! ចឹងអ្នកមីងតើជីដូនជីតាឪពុកម្តាយអីគាត់ធ្លាប់ទៅរស់នៅប្រទេសក្រៅហោ?

ខ៖ អត់ដែល។

ក៖ អត់ដែលសោះ?

ខ៖ នៅស្រុកខ្មែររហូត។

ក៖ ចាស! ហ្នឹងហើយ ចឹងអ្នកមីងសម្រាប់ការសិក្សាអ្នកមីងវិញម្តង អ្នកមីងរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ បានត្រឹមថ្នាក់ទី៣។

ក៖ ទី៣ហោ?

ខ៖ ការងារច្រើនពេក គាត់ប្រើអត់អោយទៅរៀន គាត់វ៉ៃអត់អោយទៅរៀនម៉ង។

ក៖ ចឹងទៀត?

ខ៖ ខ្ញុំលួចរត់ទៅរៀនមកវិញគាត់រកវ៉ៃខ្ញុំដល់ពេលខ្ញុំយំផងអីផងគាត់អត់អោយទៅរៀន

ខ្ញុំលួចរត់ទៅរៀនអក្ខរកម្មពេលយប់ទៀតតស៊ូ បើសិនឪពុកម្តាយខ្ញុំអោយរៀនពេញលេញខ្ញុំរៀនបានច្រើនណាស់។

ក៖ ចាស!

ខ៖ ខ្ញុំតស៊ូណាស់រៀនដេញវ៉ៃផងអីផងអត់អោយទៅរៀបានថាឪពុកប្រើអោយទៅធ្វើអី ក៏ដោយអោយតែគាត់ទៅរៀន ព្រលឹមឡើងក្រោកបោសផ្ទះ លាងឆ្នាំង ដុសចានរួចបានបានទៅរៀន មកពីរៀនវិញរត់រកស្មៅសេះ កណ្តាលចម្ការម្នាក់ឯងមិនដែលបានទៅដើរលេងឯណានឹងគ្នាទេ។

ក៖ ចាស!

ខ៖ ការងារគ្រប់សព្វតាំងពីតូចមកម៉ង ដឹងក្តីមកវេទនាណាស់។

ក៖ ចុះអ្នកមីងពេលរៀន រៀននៅសាលាណាដែរ?

ខ៖  រៀននៅសាលាបឋម។

ក៖ បឋមសិក្សាឈ្មោះអីដែរមីង?

ខ៖ ទន្លេបិទ!

ក៖ ទន្លេបិទ?

ខ៖ ចាស!

ក៖  ចាស!  ចឹងមីងពេលក្តីស្រម៉ៃខ្ញុំដឹងថាអ្នកមីងទៅរៀនហ្នឹងសុទ្ធតែរត់ទៅរៀនអីផង  ចង់រត់ទៅរៀនហ្នឹង តើមីងក្តីស្រម៉ៃចង់ធ្វើអីគេបានទៅចឹង?

ខ៖  រៀន  បើពីតូចមករៀនចង់រៀនអោយចេះដឹងជ្រៅជ្រះចឹងទៅ  ស្រួលយើងប្រកបមុខរបរអីមួយស្រួលចឹង។ ចាស! រៀនថាធ្វើគ្រូអីអត់សង្ឃឹមទេព្រោះអីអត់មានក្តីសង្ឃឹមព្រោះឪពុកយើងមិនឱ្យរៀន។

ក៖ ចាស!

ខ៖ ថាអោយរៀនចេះដឹងអីអោយយើងអាចទីមុខទៅអាចរកស៊ីអី អាចស្រួលចឹងហា។

ក៖ ចាស!

ខ៖  រៀនបានត្រឹមថ្នាក់ទី៣ប្រលងចូលថ្នាក់ទី៤  គាត់ឱ្យ  ឈប់រៀនម៉ង  លួចទៅរៀន លួចទៅរៀនគួរបាន១ខែដែរ លួចទៅរៀនគួរហ្នឹងលួចទៅរៀន ។

ក៖ ចាស! អ្នកមីងចេះអានចេះសរសេរអស់ទេ?

ខ៖  ចាស?

ក៖ ចេះអានចេះសរសេរអីអស់អត់?

ខ៖ ចេះដែរ ចេះល្មម អត់ចេះច្រើនដូចគេទេ។

ក៖  ចាស តែអាចមើលរួចហោ?

ខ៖ ចាស! មើលបាន។

ក៖ ចាស! ចឹងអ្នកមីង តើក្រុមគ្រួសារអ្នកមីងធ្វើស្រែចម្ការឬក៏រកស៊ី?

ខ៖ អើ បែកពីអាពតមកហ្ន?

ក៖ ចាស!

ខ៖ បែកពីអាពតមក ដឹងក្តីមករកស៊ីរហូត។

ក៖ លក់ដូរអីចឹងទៅមីងហេ?

ខ៖ ចាស! ប្រកបអាជីវកម្មខាងលក់ដូរម៉ង។

ក៖ ចាស!

ខ៖ ហើយឪពុកខ្ញុំគាត់ខាងប៉ះកង់ ឡាន។

ក៖ ចាស ចឹងតើអ្នកមីងរៀបការនៅថ្ងៃខែឆ្នាំណាដែរអ្នកមីង?

ខ៖ ការនៅឆ្នាំ១៩៨៦។

ក៖ ១៩៨៦! មីងការនៅឯណាវិញ?

ខ៖ ការនៅទន្លេបិទហ្នឹង។

ក៖ ទន្លេបិទហ្នឹងដែរ? តើការរៀបការហ្នឹងឪពុកម្តាយជាអ្នករៀបចំឱ្យឬក៏ស្រលាញ់គ្នាដោយចិត្តឯងអ្នកមីង?

ខ៖ ឪពុកម្តាយជាអ្នករៀបចំឱ្យ។

ក៖ តើធ្លាប់ឃើញប្តីពីមុនមកទេ?

ខ៖ គេនៅស្រុកតាកែវហ្ន នៅស្រុកឆ្ងាយ។

ក៖ ចាស!

ខ៖ តែគេមកលេងពូគេនៅជិតផ្ទះហ្នឹង គេឃើញគេហៅម៉ែឪគេមកដណ្តឹងម៉ង។

ក៖ ចាស អ្នកមីងស្អាត ចឹងជួបគ្នាដំបូង ថ្ងៃដំបូងជួបគ្នាជាមួយស្វាមីមីងហា នៅឯណាវិញ?

ខ៖ នៅហ្នឹងផ្ទះនឹងទន្លេបិទហ្នឹងម៉ង អត់ដែលដើរទៅណាទេ។

កៈ អត់ដែលដើរលេងជាមួយគ្នាមុនការ?

ខៈ អត់ដែលដើរ បើឪពុកញ៉ុមតឹងណាស់អត់ដែលឱ្យដើរទេ គ្រាន់តែល្ខោនលេង សុំទៅមើលអត់ឱ្យទៅមើល គេទៅស្ទាត់ស្រុកអស់ អត់ឱ្យទៅសុខចិត្តអោបសសរយំ អត់ឱ្យដើរ ម៉ង។ ហើយបើសិនគេលេងនៅវត្ត បានលេងនៅវត្តមើលម្តង ទៅមើលដែរ ប៉ុនមកដល់ធ្វើម៉េចមកដល់ផ្ទះមុនគេ បើមកក្រោយគេគាត់វ៉ៃ។

កៈ ចឹងទៀត?

ខៈ ចាស អត់ដែលបានមើលចប់ មើលហើយរត់មកផ្ទះមុនហា ហ្វើយពិបាកណាស់។

កៈ ចឹងមីងសម្រាប់ប្រៀបធៀបជីវិតមីងពីអតីតកាលហាមកបច្ចុប្បន្នកាលហ្នឹងវាខុសគ្នាម៉េចដែរមីង?

ខៈ ខុស បានមានស្វាមីហើយហ្នឹងទេរាងធូរតិច។

កៈ រៀងធូរម៉េច?

ខៈ ដូចថាប្តីយើងគេមិនចេះដើរលេងមិនចេះផឹកអីចឹងហា។

កៈ ចាស!

ខៈ ដឹងតែរកហា ដឹង តែធ្វើ។

កៈ ចាស!

ខៈ ដូចថាការហើយក៏នៅជាមួយឪពុកម្តាយដែរ នៅក៏ពិបាកឪពុកម្តាយដែរ តែមិនដឹងធ្វើយ៉ាងម៉េច បើយើងទាល់ហើយចេះតែនៅទៅ។

កៈ ចាស។

ខៈ ល្មមថាយើងមក នៅបែកហើយបានយើងធូរ។

កៈ ចាសហ្នឹងហើយ ចឹងមីងសម្រាប់ម្ហូបដែលមីងចូលចិត្តពិសារម្ហូបអីគេដែរ?

ខៈ ខ្ញុំចូលចិត្តសម្លរទឹក។

កៈ សម្លរទឹកហោ?

ខៈ ព្រោះខ្ញុំធ្វើការហាត់ ធ្វើការដូចប្រុសចឹង។

កៈ ចាស!

ខៈ  ព្រោះអីខ្ញុំកាលឆ្នាំ១៩៨៩ ម្ដាយខ្ញុះគាត់ទៅស្ទឹងត្រែងបាត់ចឹងញ៉ុមនៅប៉ះកង់ឡាន។

កៈ ចាស!

ខៈ ខ្ញុំចេះប៉ះ ចេះពត់ ចេះដោះកង់ឡាន លើខ្ញុំទាំងអស់។

កៈ កង់ឡានធ្ងន់ហាណាស់មីង។

ខៈ ធ្ងន់ តែយើងធ្វើម៉េច ចឹងបានខ្ញុំថាការងារប្រុសការងារស្អីលើខ្ញុំទាំងអស់។

កៈ ចំប៉ះកង់ឡានអ្នកមីង។

ខៈ ប៉ងកង់ឡាន ធាក់នឹងជើង បាពោះវៀន ធ្វើអីចេះទាំងអស់។

កៈ ចុះឥឡូវនៅបរហ្នឹងទៀតទេ?

ខៈ អត់ដឹងដល់ខ្ញុំយកប្ដីមក ខ្ញុំឈប់ធ្វើ។

កៈ ចាស។ ព្

ខៈ មានប្ដីមកឈប់ធ្វើ។

កៈ ចឹងពេលទំនេរអ្នកមីងចូលចិត្តធ្វើអីគេជាងគេ?

ខៈ ខ្ញុំហ្អ?

កៈ ចាស!

ខៈ ហ្អខ្ញុំស្អីក៏ធ្វើដែរអត់រើសមុខ ធ្វើទាំងអស់។

កៈ ចាស!

ខៈ អត់រើសមុខ។

កៈ ប៉ះអីធ្វើហ្នឹងម៉ង?

ខៈ ធ្វើទាំងអស់ ស្អីក៏ខ្ញុំធ្វើដែរ។

កៈ ចាស! ចឹងអ្នកមីងចូលចិត្តស្ដាប់ចម្រៀង ចូលចិត្តស្ដាប់អីទេ?

ខ៖ ចូលចិត្តតើ។

ក៖ ចូលចិត្តដែរហោ? ចាស ចូលចិត្តស្ដាប់ចម្រៀងបែបណាដែរ?

ខ៖ ខ្ញុំចូលចិត្តខាងសង់ទីម៉ង់ អត់ចូលចិត្តអាខាងកន្ទ្រាក់ញាប់ញ័រ។

ក៖ ចុះប្រសិនបើមានបុណ្យទានគេចាក់ធុងបាស់រាំ អ្នកមីងចូលចិត្តទេ?

ខ៖ ចាស?

ក៖ ចូលចិត្តរាំអីទេ?

ខ៖ ពីមុនអត់សូវចូលចិត្តឥឡូវចូលចិត្តតិចដែរ បើមាននេះទៅនាំក្មេងមើលតិចទៅមកផ្ទះវិញ។

ក៖ ចាស ហ្នឹងហើយ។

ខ៖ ដោយពេលថាថ្ងៃណាដែលសប្បាយចិត្ត ចិត្តចង់ទៅ សប្បាយចិត្តទៅ។

ក៖ ចាស តាមចិត្ត។

ខ៖ ហ្នឹងហើយ

ក៖ ចឹងអ្នកមីងតើអ្នកមីងចេះច្រៀង ឬក៏ចេះលេងឧបករណ៍តន្ត្រីអីខ្លះអត់?

ខ៖ អត់ចេះ។

ក៖ អត់សោះម៉ងហោ?

ខ៖ បើចម្រៀងច្រៀងអីចេះ ចេះច្រើនដែរ តែខ្ញុំមិនសូវយកចិត្តទុកដាក់។

ក៖ ចាស។

ខ៖ បើកាលនៅរៀនខ្ញុំចេះច្រើនចម្រៀងហ្នួ។

ក៖ ចាស!

ខ៖ ព្រោះអីគ្រូបង្រៀន ខ្ញុំបានអើរៀន រៀន អាខាងអើគេហៅកុមារឈានមុខហា។

ក៖ ចាស!

ខ៖ ហ្នឹងហើយចម្រៀងច្រើនណាស់ពីរ បី ក្បាលសៀវភៅ។

កៈ ចាស ហ្នឹងហើយ ចឹងអ្នកមីងតើអើសូមប្រាប់ពីជីវប្រវត្តិអ្នកមីងពេលនេះហា នៅជំនាន់សង្គ្រាម ប៉ុល ពត ឥវ៉ាន់ចឹងហា ថាអ្នកមីងជួបរឿងអីគេខ្លះសូមរៀបរាប់អោយក្បោះក្បាយចឹងហា?

ខៈ ខ្ញុំជំនាន់ប៉ុល ពត ញ៉ុមនៅតូច។

កៈ ចាស ចាំអីអត់?

ខៈ ចាំ គ្រាន់តែថាគេបាញ់គ្នាទៅយើងរត់ទៅឆ្ងាយចឹងទៅរត់គេចពីគ្រាប់ពីអីចឹងទៅឆ្ងាយហើយដល់ពេលស្ងាប់គ្រាប់រត់មកវិញ។

កៈ ចាស!

ខៈ រត់តាមគេតាមឯងរត់ទៅចេះតែទៅហា។

កៈ ជាមួយបងប្អូនដែរ?

ខៈ ជាមួយម៉ែឪហ្នឹងហា ម៉ែឪគាត់នាំទៅ កាលហ្នឹងខ្ញុំនៅតូចថាគាត់យកចិត្តទុកដាក់។

កៈ ប៉ុន្មានឆ្នាំពេលហ្នឹង?

ខៈ ជំនាន់ហ្នឹង ប្រាំ ប្រាំមួយឆ្នាំហ្នឹង ប៉ុល ពត។

កៈ ចាស ចុះមីងនៅឆ្នាំ១៩៧៤ ៧៥អីហ្នឹង?

ខៈ អត់ទេ ៦៨(១៩៦៨) ៧ ឬ ៨ឆ្នាំអីហើយ។

កៈ ចុះពេលហ្នឹងគេប្រើមីងឱ្យធ្វើអីគេដែរ?

ខៈ ថាអោយមើលតែប្អូនទេ ប្អូន២លើខ្ញុំទាំងអស់។

កៈ ចុះអាពតអត់មានអោយទៅកើបអាចម៍គោអីទេហី?

ខៈ អត់ទេ គេអោយយើងមើលប្អូន កូនចៅគេ គេឱ្យយាយៗមើល ចំនែកខ្ញុំគេឱ្យខ្ញុំមើល ប្អូន ប្អូន២នាក់។

កៈ គេចាត់ចឹងម៉ង?

ខៈ ចាស! ម៉ែខ្ញុំថាមិនបាច់ឱ្យទៅធ្វើអីទេ ឱ្យនៅមើលប្អូនហើយ ព្រោះម្ដាយគាត់ទៅសហករណ៍ហើយ ទៅធ្វើការអោយគេហ្នា យើងមើលប្អូនទៅ។

កៈ ចាស ចឹងអ្នកមីងហាត់ដែរ?

ខៈ ហ្នឹងហើយនៅក្មេងនៅតូចដែរគេយកធ្វើអីអត់កើត។

កៈ ចាស!

ខៈ បានត្រឹមមើលប្អូន ហ្នឹង។

កៈ ចាស ចឹងអ្នកមីងការហូបចុកពេលហ្នឹងម៉េចដែរគ្រប់គ្រាន់ទេ?

ខៈ ហួអត់គ្រប់ទេ តែបបរដាក់គ្រាប់ពោត ស្ងោរគ្រាប់ពោតធ្វើបបរ។

កៈ ចាស!

ខៈ អត់ដែល មានបាយហូបទេជំនាន់ប៉ុលពតហ្ន។

កៈ ហើយរាងម៉េចវិញទៅមីងចឹង ស្គមអីទេ?

ខៈ នៅក្មេង ស្គម ឡើងក្រញែសៗហ្នឹង។

កៈ ចាស! ឥឡូវរាងសាច់ឈាមស្រស់ថ្លាតិច។

ខៈ ចាស យើងសម័យនេះហើយវាបរបូគ្រាប់គ្រាន់។

កៈ ចាស!

ខៈ ហូបចុកអីជំនាន់អាពតពិបាកដែរ តែពិបាកដុំៗចឹងហា។

កៈ ចាស!

ខៈ យើងថាមិន ពេល បាយអីចឹងទៅពិបាកគេមិនដែលមានបាយឱ្យយើងហូប បបរគ្រាប់ពោតអីចឹងទៅ បបរអង្ករមួយៗចឹងទៅលាយគ្រាប់ពោត។

កៈ ចាស! ចុះសម្រាប់ជីវិតរបស់ឪពុកម្ដាយអ្នកមីងវិញគាត់ម៉េចដែរ?

ខៈ ឪពុកម្ដាយខ្ញុំគាត់ទៅសហករណ៍គាត់ចេញទៅបាត់ៗចឹងទៅ ខ្ញុំមកធ្វើការគេចាត់មកខាងឃុំអីចឹងទៅ។

កៈ ចាស!

ខៈ ម៉ែខ្ញុំគាត់ទៅធ្វើកាតដូចថាទៅដាំពោត ដាំថ្នាំអីចឹងទៅ ជំនាន់ ប៉ុល ពត ខ្ញុំនៅទូលគរហ្ន។

កៈ ចាស! ចុះគាត់មានដែលប្រាប់ទេពេលមកផ្ទះវិញឬក៏ពេលបែក ប៉ុល ពត មកគាត់មានដែលប្រាប់ពីជីវិតរបស់គាត់ទេមីង?

ខៈ ដូចអត់ដែលនិយាយប្រាប់ផង។

កៈ ចាស! ហើយមីងមានដែលឃើញគេយកមនុស្សទៅសម្លាប់នៅហ្នឹងភ្នែកអីដែរទេ?

ខៈ អត់ដែលទេ ដែលតែគេធ្លាប់យកខ្ញុំមកសម្លាប់ចោលតែបានគេជួយហា។

កៈ ចាស! ម៉េចវិញមីង គេដឹកម៉េចដែរ?

ខៈ គេដាក់កាណូត កាលហ្នឹងជំនាន់ខែទឹកឡើងហា១៩៧៨ហ្នឹង។

កៈ ចាស!

ខៈ ជិតដាច់៧៨ ជិតចូល៧៩ ទឹកឡើងធំមែនទែនហ្នឹង គេដាក់ទូកយកមក។

កៈ ចាស!

ខៈ មកដល់ទើរត្រឹម ហ្នឹងទន្លេបិទហ្នឹង។

កៈ ចាស!

ខៈ ប្រុងបញ្ជូនដាក់លើឡានទៅសម្លាប់ហើយហ្នឹង ប៉ុនបានមេ ភូមិគេជួយ ជួយថាគ្រួសារហ្នឹងមិនដែលធ្វើអីខុសចឹងហា ហើយគេអោយទៅវិញ កុំអីត្រូវស្លាប់ បាត់ហើយ។

កៈ ហើយពេលហ្នឹងមីងអត់សូវដឹងអីណាហីថាគេយកទៅណាហី?

ខៈ អត់អត់សូវដឹងថាគេយកទៅវៃចោល ដំតែរ្យួចម៉ែគាត់និយាយប្រាប់។ ក្មេងពីជំនាន់នោះមិនដឹងដូចក្មេងជំនាន់ឥឡូវទេ។

កៈ ចាស!

ខៈ ដូចល្ងង់ហា។

កៈ ហ្នឹងហើយ។

ខៈ ដឹងថាបានជិះទូកសប្បាយ បានជិះទូក មិនដឹងគេយកទៅវៃចោល។

កៈ ហ្នឹងហើយ ដោយសារនៅក្មេងពេកចឹងអត់ដឹងទេ។

ខ៖ នៅក្មេង ក្មេងជំនាន់ហ្នឹងអត់សូវចេះដឹងដូចក្មេងឥឡូវ។

ក៖  ចាស!

ខ៖ ល្ងង់ណាស់។

ក៖ ចាស ចឹងអ្នកមីងសល់បងប្អូនសាច់ញាតិណាខ្លះពីជំនាន់ប៉ុល ពតហ្នឹងហោ?

ខ៖ ជំនាន់ប៉ុល ពតហោ?

ក៖ ចាស!

ខ៖ សល់នៅសាច់ញាតិច្រើនតើ។

ក៖ ចាស! អ្នកណាគេខ្លះមីង?

ខ៖ នៅបងប្អូន បើបងប្អូនជំនាន់ ប៉ុល ពត ដូចអត់មានស្លាប់ទេនៅទាំងអស់។

ក៖ ចាស!

ខ៖ ចាស បងទើបមកធ្វើទាហានហ្នឹង ក្រោយករវេហ្នឹងគេបាញ់សម្លាប់ ទៅធ្វើទាហាន មកវិញគេបាញ់ ។

ក៖ ចាស!

ខ៖ ខ្មែរក្រហមបាញ់ត្រូវ។

ក៖ ចាស! មីងពេលបែក ប៉ុល ពត ហ្នឹងមានសល់ទាហានខ្មែរក្រហមច្រើនទេ?

ខ៖ សល់ច្រើនដែរហ្នឹង។

ក៖ ចាស!

ខ៖ ខ្មែរក្រហមសល់ច្រើនដែរហ្នឹង។

ក៖  ពិបាកណាស់មីងណោស?

ខ៖ ពិបាក!

ក៖  ចឹងសម្រាប់ជីវិតមីងហាអ្វីដែលមីងចងចាំជាងគេក្នុងជីវិតរបស់មីងហា?

ខ៖ ខ្ញុំចងចាំថាតាំងពីកើតដឹងក្តីមកពិបាករហូតអត់ដែលបានសប្បាយនឹងគេ។

កៈ ចឹងពេលវេលាដែលសប្បាយជាងគេអីគេវិញ?

ខៈ សប្បាយជាងគេគឺថាពេលមានគ្រួសារហើយ។

កៈ ម៉េចវិញមីង?

ខៈ ដូចថាសប្បាយ ដូចថាយើងចង់ដើរលេងអីមានអីលេងចឹងដូចថាគេមិនសូវចេះហាមឃាត់យើងចឹងហា។

កៈ ចាស សេរីភាពច្រើន។

ខៈ ចាស! យើងមានសេរីភាពជាងកាលនៅជាមួយឪពុកម្តាយ។

កៈ អត់ដូចខ្ញុំទេ ខ្ញុំវិញមានសេរីភាពពេញទីម៉ងមីង។

ខៈ គេដឹងថាកាលនៅជាមួយឪពុកម្តាយគេបិទ បិទសិទ្ធយើងអត់អោយដើរលេងចឹងហា ពេលបានប្តីមកគេមិនសូវបិទសិទ្ធយើងទេ។

កៈ ចាស!

ខៈ បានសប្បាយខ្លះ។

កៈ ខ្ញុំយល់អារម្មណ៍ដែលយើងចង់ទៅឯណាហើយគេអត់អោយទៅពិបាកហាណាំ។

ខៈ ចាស ពិបាកយំ។

កៈ ខ្ញុំវិញដល់ពេលពីតូចហ្នឹងអត់អោយចេញទៅណា ដល់ពេលខ្ញុំធំចឹងសេរីភាពខ្ញុំម៉ង

ខៈ ចាស!

កៈ ខ្ញុំមកកំពង់ចាមចឹង ខ្ញុំជិះម៉ូតូមកតែម្នាក់ឯងហ្នឹងមីង ប៉ុន្តែដោយសារម៉ែ បងប្អូនអីគាត់ទុកចិត្តចឹងហា។

ខៈ ចាស!

កៈដោយសារខ្ញុំស្គាល់មនុស្សច្រើនចឹងទៅគាត់ទុកចិត្តខ្ញុំ ខ្ញុំអាចនៅជាមួយខ្ញុំស្គាល់បាន។

ខៈ ហ្នឹងមកពីឪពុកម្តាយយើងមានជីវភាពធូរធារ បើឪពុកម្តាយខ្ញុំគាត់ពិបាក។

កៈ ចាស!

ខ៖ ហើយណាមួយគាត់ហៅប្រើយើង ការងារ១០០ជំពូកលើយើងទាំងអស់ យើងទៅណាអត់បាន។

ក៖ ចាស!

ខ៖ ចាស! ដូចដល់ម៉ោងស្មៅសេះ ស្មៅសេះហា ទៅមកពីរៀនវិញ គ្រាន់តែបាយមិនបានហូបផងរត់ទៅបោចស្មៅសេះ មកបោចស្មៅសេះចឹងទៅរៀន ជួនកាលថាហ្ហ គេដងត្រីត្រូវណាស់ទៅដងត្រីនឹងគេ រត់ទៅដងត្រីទៅ ដងត្រីទន្លេ។

ក៖ បានត្រីច្រើនទេមីង?

ខ៖ បាន។ អត់អុសដុតប្រើទៅទៅច្រូតស្មៅសេះទៅដាក់យើងចោលក្នុងព្រៃរកអុសម្នាក់ឯង

ចឹងគាត់ ទៅរកស្មៅសេះមក ទំរាំគាត់ច្រូតបានពេញបាវចឹងមក មកយកយើងវិញ រកអុសមកបានមកទាំងអស់គ្នាចឹង អាហ្នឹងចឹង។

ក៖ ចាស! ចឹងអ្នកមីងកាលមីងរៀបអាពាហ៍ពិពាហ៍ហើយមីងមានកូនប៉ុន្មាននាក់វិញ?

ខ៖ ខ្ញុំមានកូន៤។

ក៖ ៤? ស្រីប៉ុន្មាន ប្រុសប៉ុន្មានមីង?

ខ៖ ប្រុសទាំងអស់។

ក៖ ងាប់បណ្តោយ។ ឈ្មោះអីគេខ្លះមីង តាំងពីបងរហូតដល់ពៅហា។

ខ៖ បងគេ ឈ្មោះ សក សុខណា បន្ទាប់មក សក សុខនី បន្ទាប់មក សក សុខនឿន ក្រោយមក សក សុខសំណាង។

ក៖ សុខហើយសំណាងទៀត?

ខ៖ ចាស!

ក៖ ចឹងអ្នកមីងតើស្វាមីអ្នកមីងគាត់ឈ្មោះអីគេដែរ?

ខ៖ ក្នុងបញ្ជីជាតិ ឈ្មោះ ប្រាក់ សាមិត្ត។

ក៖ ចាស មានហៅក្រៅអីទេ?

ខ៖ ហៅក្រៅគេហៅពួយ។

កៈ ពួយ?

ខៈ ពួយរហូត ។

កៈ គាត់ប៉ុនរកពេកមែនបានគេហៅពួយមីង?

ខៈ បើថារកមិនសូវចេះរកណាម៉ានដែរហ្នឹងហា មិនសូវជារក។

កៈ អ្នកមីងប្តីអ្នកមីងគាត់ម៉េចដែរជាមនុស្សដែលចរិកម៉េចដែរ?

ខៈ មនុស្សដែលមានចរិកដែលថាសុភាពស្លូតបូតដូចថាមិនសូវចេះរញ៉េរញ៉ៃច្រើន។

កៈ ចាស!

ខៈ គាត់ដឹងតែពីធ្វើចឹងហា អាកាលយកខ្ញុំដំបូងហា។

កៈ ចាស!

ខៈ ទើបតែឥឡូវហ្នឹងទេបានមកកូនក្រោយ ចេះខូច ចេះផឹក ខ្ញុំពិបាកចិត្ត ចាប់ផ្តើមអាពិបាកចិត្តអាប្តីចេះផឹកហ្នឹង ចង់ធ្លាក់កំរិតដើមវិញហើយ យើងពិបាកពីមុនមក។

កៈ ចាស! ចុះដល់ពេលនិយាយគាត់គាត់អត់ស្តាប់មែនបានចឹង?

ខៈ និយាយអត់បាន បានផឹកហើយផឹករហូត បើផឹកថាមិនរករឿងអីរកអីចឹងហា។

កៈ ចាស! តែផឹកគាត់រក។

ខៈ មែនថាជេរ ប្រចោរអីទេណា។ ទៅរត់ម៉ូតូបានមកដែរ តែបានមកទិញស្រាផឹកអស់ ត្រង់ហ្នឹងហើយថាពិបាក។

កៈ ចាស ចឹងអ្នកមីងសម្រាប់រាល់ថ្ងៃសម្រាប់អ្នកមីងម៉ងហាមីងប្រកបរបរអីចិញ្ចឹមជីវិតដែរចឹង?

ខៈ រាល់ថ្ងៃអត់រកអីទេនៅមើលចៅ។

កៈ មើលចៅ?

ខៈ មើលកូនអោយគេ អាកូនមួយទៅធ្វើការរោចក្រ។

កៈ ចាស ហើយបានអីគេផ្គត់ផ្គង់សម្រាប់ជិវិតសព្វថ្ងៃអីចឹងហា?

ខ៖ ជូនកាលអីទៅគេបើកប្រាក់ខែអោយមកប្អូនដប់មឺនអីចឹងទៅយើងរិះថាំ។

ក៖ ចាស ហើយស្វាមី ដល់ពេលអត់មានអីនៅក្នុងផ្ទះចឹងគាត់គួរតែទៅរក។

ខ៖ រកទៅ ២ ឬ ៣ថ្ងៃបាន។ ៤ឬ៥ថ្ងៃ បាន៤០០០ទៅ៥០០០ចឹងទៅបាន១០០០០អីចឹងទៅ។

ក៖ ចាយអីគេគ្រាន់ទៅមីងលុយប៉ុណ្ណឹង។

ខ៖ យើងទាល់តែព្រឹតព្រៀងខ្លាំង។

ក៖ ចាស។ ចឹងអ្នកមីងរបៀបដើម្បីមីងចិញ្ចឹមអប់រំថែរក្សាកូនអ្នកមីងអប់រំពួកគាត់យ៉ាងម៉េចដែរ?

ខ៖ ខ្ញុំអប់រំឱ្យវាដើរតាមផ្លូវល្អដូចថាសង្គមគេស្អប់ខ្ពើមចឹងកុំទៅជិតចឹង។ ចាស កូនធ្វើតែល្អទៅកន្លែងណាមានរឿងរ៉ាវអី ឈ្លោះប្រកែកគ្នាអីដើរចេញអោយឆ្ងាយទៅកុំចង់ចាញ់កុំចងឈ្នះអីគេគេ តែប៉ុណ្ណឹង។

ក៖ ចាស!

ខ៖ អប់រំកូនថាធ្វើម៉េចយើងរកស៊ីទៅមកដល់ផ្ទះយើងដេក ទៅកុំសន្សំរឿងជាមួយគេចឹងហា។
ក៖ ចាស!

ខ៖ សង្គមឥឡូវកន្លែងណាដែលគេសង្គម ស្អប់ ខ្ពើមកុំទៅជិត ចាស ហើយត្រូវជៀសឱ្យឆ្ងាយ។

ក៖ ចឹងអ្នកមីង តើដូចជា តើអ្នកមីងធ្វើដូចម្តេចដើម្បីអោយក្រុមគ្រួសារមានសុភមង្គលអត់ឈ្លោះប្រកែកគ្នាអត់អីចឹងហា?

ខ៖ អត់ឈ្លោះគ្នាលុះត្រាតែពួកយើងអត់ចេះអត់ឱនអោយគ្នាហា អត់ឱនអោយខ្លាំងណាស់បើចឹងឈ្លោះរាល់ថ្ងៃបើថាប្តីផឹក បិនថាយើងចេះតែអត់ យើងចេះតែទ្រាំទៅ បើបានជាគ្នាទៅហើយចំណាស់ហ្នឹងមានដល់ទៅចៅទៅហើយ ខ្ជិល។

ក៖ ខ្ជិលមាត់ម៉ងមីងហេ?

ខ៖ ចាស ចេះតែទ្រាំទៅ។

ក៖ អាយុប៉ុន្មានប្តីមីង។

ខ៖ ៥០!

កៈ ៥០ហើយនៅតែផឹកទៀត។

ខៈ ហ្នឹងនៅប៉ុន្មាន១០ឆ្នាំជាងហ្នឹងមកខូចម៉ង។

កៈ ចាស ចឹងពេលដែលអ្នកមីងមានបញ្ហាវិធីដើម្បីមីងដោះស្រាយមីងធ្វើយ៉ាងម៉េចទៅ?

ខៈ បើមានបញ្ហា បើគេរអ៊ូខ្លាំងយើងដើរចេញ ដើរគេចទៅ។

កៈ ចាស!

ខៈ កុំឱ្យមានរឿង។

កៈ ដល់ពេលស្ងំទៅចាំដោះស្រាយ។

ខៈ ចាស ហ្នឹងហើយ។

កៈ ចាស! ចឹងអ្នកមីងតើគ្រួសារមានអន្ថន័យយ៉ាងម៉េចចំពោះអ្នកមីងដែរ?

ខៈ គ្រួសារខ្ញុំរាល់ថ្ងៃហ្នឹងហេ ដូចន័យវាតិចតួចមែនទែនហា រស់រាល់ថ្ងៃន័យតិចតួចមែនទែនហា។

កៈ តើអ្នកមីងអាចរស់នៅខ្វះពួកគាត់បានទេ?

ខៈ តែខ្វះអត់បាន។

កៈ តែវាអត់សូវមានន័យច្រើន តែខ្វះអត់បាន ហ៊ីហ្នឹងមានន័យខ្លាំងហើយមីង។

ខៈ នឹកឃើញម្ដងៗមិនចង់រស់ គ្មានន័យ នឹកឃើញថាកូនយើងទៅណាចោលកូនយើងវាមិនរួច។

កៈ ចាស!

ខៈ មានកូនមានចៅចឹងហើយ ចេះនឹកឃើញអនាគតកូនវែងឆ្ងាយអីចឹងទៅណា។

កៈ ចាស! ហ្នឹងហើយ ចឹងតើអ្នកមីងមានបទពិសោធន៍អីខ្លះដែលល្អនៅក្នុងជីវិតដែលចង់ចែកចាយទៅកាន់កូនចៅជំនាន់ក្រោយហា?

ខៈ ខ្ញុំបទពិសោធន៍តិចណាស់ តែចង់តែឱ្យកូនអោយវារៀនអោយបានច្រើនទៅ ឱ្យវាមានមុខរបររកគ្រប់គ្នាទៅ ដើម្បីឱ្យអនាគតរបស់ពួកវា វាមានអនាគតល្អយើងល្អហើយ។

ក៖ ចាស!

ខ៖ រាល់ថ្ងៃជួយឱ្យកូនមានអនគតល្អ គិតពីអនាគតកូន។

ក៖ ចាស!

ខ៖ ចំណាស់នេះហើយវាមានប៉ុន្មានទៀតទេ៥០ស្អែកខានស្អែកហើយ។

ក៖ ចាស ចឹងអ្នកមីងមួយនេះជាសំនួរមួយចុងក្រោយហាអ្នកមីង តើអ្នកមីងមានដំបូន្មានអីគេខ្លះ ដែលចង់ចែកចាយកូនចៅមីងជំនាន់ក្រោយ ព្រោះថាពួកគាត់នឹងស្តាប់ឮសម្តីរបស់អ្នកមីងចឹង ពួកគាត់អត់ទាន់កើតទេឥឡូវហ្នូ ប៉ុន្តែដំបូន្មានដែលអ្នកមីងចង់ផ្តាំផ្ញើរគាត់ចឹងហាឱ្យគាត់ដើរលើផ្លូវយ៉ាងម៉េចដែរអ្នកមីង?

ខ៖ ចាស! ខ្ញុំចង់ផ្តាំផ្ញើរថាកូនអើយសង្គមឥឡូវ សង្គមគេមានអាថាដូចថាជក់ម៉ាអីចឹងទៅភ្លើតភ្លើនច្រើន តែកូនកុំដើរចូលទៅកន្លងដែលថាមិនល្អកូនត្រូវធ្វើម៉េចដែរសង្គមគេស្អប់ហើយកូនជៀសអោយឆ្ងាយ ដើម្បីអោយសង្គមយើងរីកចម្រើន យើងកុំដើរផ្លូវអាក្រក់ ធ្វើម៉េចដើរលើផ្លូវល្អ បានល្អហើយកូនអើយ។

ក៖ ចាស!

ខ៖ ចឹងចាស ដើម្បីអនាគតកូន កូនត្រូវធ្វើម៉េចស្តាប់ ដំបូន្មានឪពុកម្តាយ។

ក៖ ចាស!

ខ៖ មិនដែលប្រដែរប្រដៅកូនឱ្យអាក្រក់ទេ។

ក៖ ចាស ចឹងជៀសផុតពីផ្លូវអីគេដែរមីង?

ខ៖ ហ្នឹងហើយ ចង់អោយកូនជៀសផុតពីផ្លូវដែរថាគេមិនរក គេមិនរាប់រកកូនកុំចូល។

ក៖ ចាស!

ខ៖ ហ្នឹងហើយ។

ក៖ អរគុណាមែនទែនអ្នកមីងដែលចូលសហាការណ៍នឹងពួកយើងហើយបង្កើតពីជីវប្រវត្តិអ្នកមីង ទុកអោយកូនចៅស្តាប់ជំនាន់ក្រោយចឹងហាអ្នកមីង។

ខ៖ ចាស!

ក៖ ចឹងនាងខ្ញុំសូមថ្លែងអំណរគុណ ហើយអ្វីដែលអ្នកមីងបាននិយាយពួកយើងនឹងដាក់ចូលទៅក្នុងវេបសាយដែលខ្ញុំបាននិយាយខាងលើ ចឹងសូមអរគុណអ្នកមីង។